# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

តំណាងសហព្រះរាជអាជ្ញា **ឌេល លីសាក់** ៖ *សាក្សី ! តើលោកអាចបញ្ជាក់បានដែរឬទេថា លេខាស្រុកណាខ្លះ ក្រៅពីលោក មិនត្រូវបានគេចាប់ ឬសម្លាប់ ឬក៏បាត់ខ្លួន នៅក្នុងឆ្នាំ១៩៧៧?*

សាក្សី **សៅ សារុន** ៖ *បាទ អត់មានទេ។*

## I. និន្នាភាពទូទៅ

សប្តាហ៍នេះ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីចំនួន ៣រូប សាក្សីទីមួយគឺ លោក **សគឹម ល្មុត** សាក្សីទីពីរគឺ លោក **សៅ សារុន** និងសាក្សីទីបីគឺ លោក **ខឹម ងន**។ កាលពីថ្ងៃច័ន្ទ ទី៤ ខែមិថុនា តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ **អាប់ឌុលឡាក់ ថារិក** បានបន្តសួរដេញដោលសាក្សី **សគឹម ល្មុត** ដែលជាអតីតនាយករងនៃធនាគារពាណិជ្ជកម្មក្រៅប្រទេស។ ជាបន្ទាប់ ជាវេទិការរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **ស៊ីន សុវ៉ន** និងលោក **បាណាបេ ណេគ្វី** បានសួរដេញដោលនៅថ្ងៃដដែលនោះ។ នៅថ្ងៃអង្គារ ក្រុមមេធាវី ការពារក្តីលោក **ខៀវ សំផន** មានលោក **គង់ សំអុន** និងលោក **អាកទួរ វែកគែន** បានសួរដេញដោលសាក្សី ជាបន្ទាប់ក្រុមមេធាវីការពារក្តីលោក **នួន ជា** មានលោក **សុន អរុណ** និងលោក **ហ្សាស្មើ ប៉ោ**។ ដោយឡែក ក្រុមមេធាវីការពារក្តីលោក **អៀង សារី** ពុំបានសួរដេញដោលសាក្សីរូបនេះទេ។ សក្ខីកម្មរបស់

សាក្សី **សគឹម ល្មុត** បានមកដល់ទីបញ្ចប់ ក្រោយពីលោកចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** សួរដេញដោលពាក់ព័ន្ធនឹងជនជាប់ ចោទ **ខៀវ សំផន** និងឈ្មោះហៅក្រៅ "**ហែម**"។

នារសៀលថ្ងៃទី៥ មិថុនា ២០១២ តំណាងសហព្រះរាជអាជ្ញា **សេង ប៊ុនឃាង** បានចាប់ផ្តើមសួរដេញដោលសាក្សី **សៅ សារុន** អំពីតួនាទីជាលេខាតំបន់១០៥ (មានទីតាំងនៅខេត្តមណ្ឌលគីរី)។ នៅថ្ងៃពុធទី៦ មិថុនា ២០១២ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ **ឌេល លីសាក់** បានបន្តសាកសួរសាក្សីរហូតដល់ថ្ងៃព្រហស្បតិ៍ នៅពេលអង្គជំនុំជម្រះបានសម្រេចធ្វើការកោះហៅសាក្សីថ្មី (លោក **ខឹម ងួន**) មកផ្តល់សក្ខីកម្មជំនួស ដោយសារតែស្ថានភាពសុខភាពរបស់សាក្សី **សៅ សារុន** ពុំមាំទាំ។ ក្រោយពេលចូលកាន់កាប់ទីក្រុងភ្នំពេញឆ្នាំ១៩៧៥ សាក្សី **ខឹម ងួន** ត្រូវបានចាត់តាំងឲ្យធ្វើការនៅក្រសួងការបរទេស និងទទួលបន្ទុកជាអ្នកអមដំណើរភ្ញៀវការបរទេសទៅធ្វើទស្សកិច្ចតាមបណ្តាខេត្តនានា។ ការសួរដេញដោលសាក្សី **ខឹម ងួន** ចាប់ផ្តើមដំបូងដោយតំណាងសហព្រះរាជអាជ្ញា **ច័ន្ទ តារារស្មី** និង **វាំងសង់ ដឺវ៉ាយដ៍ អេស្មាឯល** ។

## II. សេចក្តីសង្ខេបនៃការផ្តល់សក្ខីកម្ម

សាក្សី **សគឹម ល្មុត** បានមកផ្តល់សក្ខីកម្មនៅថ្ងៃច័ន្ទ និងព្រឹកថ្ងៃអង្គារ។ សហព្រះរាជអាជ្ញាបានព្យាយាមបង្ហាញពីចំណងពាក់ព័ន្ធរវាងជនជាប់ចោទ **ខៀវ សំផន** និងគណៈកម្មាធិការពាណិជ្ជកម្ម ប៉ុន្តែក្រុមមេធាវីការពារក្តីលោក **ខៀវ សំផន** បានព្យាយាមលើកថា សក្ខីកម្មរបស់សាក្សីពុំផ្អែកតាមការយល់ដឹងពីរបបកម្ពុជាប្រជាធិបតេយ្យទេ គឺបានមកពីឯកសារបង្ហាញដោយសហចៅក្រមស៊ើបអង្កេត។

ចំណែកឯសាក្សី **សៅ សារុន** បានមកផ្តល់សក្ខីកម្មនៅរសៀលថ្ងៃអង្គារ និងព្រឹកថ្ងៃព្រហស្បតិ៍។ សក្ខីកម្មរបស់សាក្សីផ្តោតសំខាន់ទៅលើ ៖ តួនាទីខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ - គោលនយោបាយបក្ស - និងការប្រាស្រ័យទាក់ទងរវាងថ្នាក់ដឹកនាំជាន់ខ្ពស់។

សាក្សីចុងក្រោយនាសប្តាហ៍នេះ គឺលោក **ខឹម ងួន** បានមកផ្តល់សក្ខីកម្មនៅថ្ងៃព្រហស្បិ៍ ស្តីពីការចូលរួមបដិវត្តន៍មុនឆ្នាំ១៩៧៥ និងតួនាទីខ្លួននៅក្រសួងការបរទេសក្រោយថ្ងៃរំដោះភ្នំពេញនៅឆ្នាំ១៩៧៥។

### ក. សក្ខីកម្មរបស់សាក្សី សគីម លុត

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ **អាប់ឌុលឡាក់** បានចាប់ផ្តើមសួរដេញដោលសាក្សី **សគីម លុត** នៅថ្ងៃច័ន្ទ ដោយផ្តោតសំខាន់លើតួនាទីរបស់ជនជាប់ចោទ **ខៀវ សំផន** និងគណៈកម្មាធិការពាណិជ្ជកម្ម។ លោក **អាប់ឌុលឡាក់** បានដាក់បង្ហាញឯកសារកម្ពុជាប្រជាធិបតេយ្យ និងអានផ្នែកខ្លះថា "សាក្សីបានប៉ាន់ស្មានថា ឈ្មោះ **អន** និង **វ៉ាន់ រិទ្ធ** (ក្លាយជាប្រធាននៃគណៈកម្មាធិការពាណិជ្ជកម្ម បន្ទាប់ពីការបាត់ខ្លួនរបស់ **ស៊ឿ វ៉ាស៊ី** ហៅ **ឌឿន**[1]) អ្នកទាំងពីរស្ថិតក្រោមបង្គាប់របស់ **វន វ៉េត** និង **ខៀវ សំផន**"។ សាក្សីនៅតែទទួលស្គាល់ចម្លើយខ្លួន ទោះបីជាគាត់បានថ្លែងថា គណៈកម្មាធិការពាណិជ្ជកម្មនាពេលនោះ គឺបានបំបែកចេញពីធនាគារពាណិជ្ជកម្មក្រៅប្រទេស (គាត់គឺជាអ្នកគ្រប់គ្រងធនាគារពាណិជ្ជកម្មក្រៅប្រទេសក្នុងនាមជានាយករង) ដោយហេតុនេះ ទើបគាត់មិនបានដឹងពីកិច្ចការរបស់គណៈកម្មាធិការពាណិជ្ជកម្ម។

តំណាងសហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** បានដាក់បង្ហាញបញ្ជីហិរញ្ញវត្ថុចំនួន ៦ច្បាប់ ស្តីពីគណនីភាពពាណិជ្ជកម្ម ធ្វើនៅខែមករា ដល់ ខែតុលា ឆ្នាំ១៩៧៨ ដើម្បីឆ្លុះបញ្ចាំងពីខ្សែសង្វាក់នៃការគ្រប់គ្រងរវាងប្រធានគណៈកម្មាធិការពាណិជ្ជកម្ម រួមមាន **វ៉ាន់ រិទ្ធ** - **ខៀវ សំផន** ហៅ "**ហែម**" - និង **វន វ៉េត** ។ លោក **អាប់ឌុលឡាក់** បានសុំឱ្យសាក្សីអាននូវចំណារដៃនៅទំព័រមុខ និងទំព័រចុងក្រោយនៃឯកសារគណនីយ ដែលមានភាពប្រហាក់ប្រហែលគ្នា (ខុសតែកាលបរិច្ឆេទ)។ ឯកសារបីច្បាប់មានហត្ថលេខា **វ៉ាន់ រិទ្ធ** ឯកសារពីរច្បាប់មានចំណារ "ផ្ញើជូនបង **ហែម** និងបង **វន**" និងឯកសារមួយច្បាប់ទៀត មានកំណត់បញ្ជាក់របស់ **វ៉ាន់ រិទ្ធ** ថា "បានផ្ញើជូនបង **ហែម**"។ សាក្សីបានបញ្ជាក់ថា គាត់បានឃើញឯកសារទាំងនេះ គឺនៅដំណាក់កាលសហចៅក្រមស៊ើបអង្កេតដាក់បង្ហាញគាត់។ ចំពោះហត្ថលេខារបស់គាត់នៅក្នុងកំណត់ហេតុនៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត គឺបញ្ជាក់ត្រឹមថា គាត់បានអានកំណត់ហេតុនោះឡើងវិញ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ **អាប់ឌុលឡាក់** បានទាញចំណាប់អារម្មណ៍សាក្សី ដោយបង្ហាញឯកសារមួយផ្សេងទៀត គឺកំណត់ត្រាដៃនៃកិច្ចប្រជុំនៅថ្ងៃទី២ ធ្នូ ១៩៧៨ ដែលសាក្សី និងជនជាប់ចោទ **អៀង សារី** (រដ្ឋមន្ត្រីក្រសួងការបរទេស) មានវត្តមាននៅក្នុងកិច្ចប្រជុំនោះ។ សាក្សីមិនបានរំឭកឃើញកិច្ចប្រជុំនោះទេ ប៉ុន្តែក្រោយពីបានអានឯកសារ គាត់ហាក់ដូចជាចម្លែកក្នុងចិត្តថា ហេតុអ្វីបានជា **អៀង សារី** ចូលរួមកិច្ច

ប្រជុំនោះ! ព្រោះកិច្ចប្រជុំនោះលើកឡើងពីបញ្ហាពាណិជ្ជកម្ម ដែលពុំជាប់ទាក់ទិនជាមួយក្រសួងការបរទេស ទាល់តែសោះ។ សាក្សីពុំបានដឹងពីមូលហេតុ ដែលកំណត់ត្រាកិច្ចប្រជុំទាំងនេះផ្ញើជូនឈ្មោះ **ហែម** និង **វ៉ាន់** (**វ៉ាន់** ប្រហែលជា សំដៅដល់ **អៀង សារី** ដែលមានឈ្មោះហៅក្រៅ "**វ៉ាន់**")។

### ១. ការសួរដេញដោលពីភាគីដើមបណ្តឹងរដ្ឋប្បវេណី

នារសៀលថ្ងៃច័ន្ទ លោកស្រីមេធាវី **ស៊ីន សុវ៉ន** និងលោកមេធាវី **បាណាបេ ណេគ្វី** ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានសួរដេញដោលសាក្សី **សគីម ល្មុត**។ លោកស្រីមេធាវី **ស៊ីន សុវ៉ន** បានសួរនាំសាក្សីពីសកម្មភាពរបស់ខ្លួននៅមុនឆ្នាំ១៩៧៥ និងអំឡុងពេលចូលកាន់កាប់ទីក្រុងភ្នំពេញ ព្រមទាំងតួនាទីរបស់សាក្សីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណែកឯ លោកមេធាវី **បាណាបេ ណេគ្វី** បានផ្តោតសំខាន់ទៅលើការងាររបស់សាក្សីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

#### *ក. សកម្មភាពរបស់សាក្សីមុន និងក្នុងកំឡុងពេលរំដោះទីក្រុងភ្នំពេញ*

មុនពេលរំដោះបានទីក្រុងភ្នំពេញ សាក្សីមានតួនាទីជាប្រធានផ្នែកឥណទាននៅធនាគារឯកជនមួយ។ សាក្សីបានឲ្យដឹងថា គាត់បានផ្តល់ថវិកាផ្ទាល់ខ្លួនមួយចំនួនជួយដល់ចលនាបដិវត្តន៍ និងបានចូលរួមវគ្គប្រជុំនានា។ នាពេលនោះ ពុំមានការលើកឡើងពីបក្សកុម្មុយនីស្តទេ។ សាក្សីបានស្គាល់ **វ៉ាន់ រិទ្ធ** មុនពេលរំដោះទីក្រុងភ្នំពេញ ពីព្រោះគាត់ធ្លាប់ជាគ្រូបង្រៀនរបស់ **វ៉ាន់ រិទ្ធ** ។ សាក្សីរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិជាមួយ **ប៉ុល ពត** ជនជាប់ចោទ **អៀង សារី** ជនជាប់ចោទ **អៀង ធីរិទ្ធ** និងជនជាប់ចោទ **ខៀវ សំផន**។ បន្ទាប់មកសាក្សីក៏បានក្លាយជាគ្រូបង្រៀននៅសាលាវិទ្យាល័យព្រះស៊ីសុវត្ថិជាមួយលោក **អៀង សារី** លោក **ខៀវ សំផន** និងលោកស្រី **អៀង ធីរិទ្ធ**។

សាក្សីបានរៀបរាប់ជូនលោកស្រីមេធាវី **ស៊ីន សុវ៉ន** ថា នាពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សាក្សីនិងគ្រួសារបានចាកចេញពីទីក្រុងភ្នំពេញទៅកាន់ស្រុកកៀនស្វាយ ដែលពេលនោះ គ្មានសហករណ៍ ហើយសាក្សីនិងគ្រួសារពុំត្រូវបានចាត់ទុកជាប្រជាជន "ថ្មី" ឬប្រជាជន "ចាស់" ដែរ។ សហករណ៍បានបង្កើតឡើងប្រហែលជា ៣សប្តាហ៍ ក្រោយពីការរំដោះ ហើយនៅក្នុងសហករណ៍រួមបណ្តុំដោយ ក្រុមបញ្ញាជន

កម្មករោងចក្រ កសិករ និង"ប្រជាជនមូលដ្ឋាន"។ កសិករ គឺពុំមែនអ្នកក្រនោះទេ ពួកគេមានគោក្របី ដែលអាចដាក់ប្រើប្រាស់នៅក្នុងសហករណ៍។

ចំពោះពិធីរៀបការនៅក្នុងសហករណ៍របស់គាត់ គឺពុំមានភ្លេងភ្លាត់ ដែលបង្ហាញពីប្រពៃណីទំនៀមទម្លាប់ និងមានសមាជិកក្រុមគ្រួសារចូលរួមអឹកធឹកនោះទេ ប៉ុន្តែសាក្សីបញ្ជាក់ថា ការរៀបការនោះពុំមែនជាការបង្ខំឡើយ។ នេះជាការអនុវត្តន៍នៅក្នុងសហគមន៍របស់គាត់ ប៉ុន្តែមិនបានដឹងពីបណ្តាសហករណ៍ផ្សេងៗទេ។

## *ខ. តួនាទីរបស់សាក្សីក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ*

ផ្អែកតាមការអះអាងរបស់សាក្សី គាត់មិនបានដឹងថា នណាជាអ្នកបញ្ជាគាត់ឲ្យចេញពីសហករណ៍ទៅទីក្រុងភ្នំពេញទេ។ ប្រធានសហករណ៍បានឲ្យដំណឹងត្រឹមថា តាមបញ្ជាថ្នាក់លើ សាក្សីត្រូវទៅទីក្រុង និងមិនបានប្រាប់ពីហេតុផលនៃការបញ្ជូននេះឡើយ។ ក្នុងគ្រានោះ អនុប្រធានសហករណ៍បាននាំគាត់ទៅទីក្រុងភ្នំពេញដោយយានជំនិះទោចក្រយាន។ នៅពេលគាត់មកដល់ទីក្រុងភ្លាម ឈ្មោះ **អន** ជាប្រធានគណៈកម្មាធិការឧហ្សាហកម្ម (ជាមនុស្សដែល សាក្សីធ្លាប់រៀនជាមួយ) បានអនុញ្ញាតឲ្យគាត់ស្នាក់នៅជាមួយ។ សាក្សីបានជួបឈ្មោះ **ខឿន** ជាប្រធាននៃ គណៈកម្មាធិការពាណិជ្ជកម្ម ប៉ុន្តែគាត់ពុំបានដឹងថា **ខឿន** ជាប្រធានមន្ទីរ ៨៧០ នាពេលនោះ។

សាក្សីបានបន្តថា គាត់បានក្លាយជានាយករងនៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៅដើមឆ្នាំ១៩៧៦ ប៉ុន្តែគាត់មិនបានទទួលបញ្ជាជាក់លាក់ពីបុគ្គលណាមួយឡើយ គឺទទួលបានឯកសារតាមនិរសារប៉ុណ្ណោះ។ នាពេលនោះ ធនាគារគឺគ្រាន់តែជានិមិត្តរូប មានបុគ្គលិកប្រចាំការពីរនាក់ ពុំមានប្រតិបត្តិការ និងពុំមានឯកសារចំណាយចំណូល។ នៅពេលមានសំណួរថា តើពេលណាគាត់រវល់បំផុត? សាក្សីបានឆ្លើយថា សកម្មភាពនៅធនាគារ គឺមានតិចតួចបំផុត ដូច្នេះគាត់អាចមានពេលទៅចិញ្ចឹមមាន់ទា និងដាំបន្លែ។

សាក្សី **សតឹម ល្មុត** បានបន្ថែមថា ការងារចម្បងរបស់គាត់ គឺមិនមែនរៀបចំបញ្ជីនាំចេញ និងនាំចូលទេ។ លោកស្រីមេធាវី **ស៊ីន សុវ៉ន** បានសួរថាតើគាត់បានឃើញរបាយការណ៍ ឬកំណត់ត្រាអាវុធយុទ្ធភណ្ឌ? សាក្សីបានថ្លែងថា គាត់មិនបានដឹងទេ ហើយបើសិនជាមានការបញ្ជូនចេញចូល គាត់ក៏ពុំមែនជាបុគ្គលទទួល

បន្ទុកលើការងារនេះដែរ ពីព្រោះជាកិច្ចការជាតិ។ ធនាគារជាតិមានទំនាក់ទំនងជាមួយប្រទេសជាច្រើន ប៉ុន្តែគណៈកម្មាធិការពាណិជ្ជកម្មជាស្ថាប័នដែលផ្សាភ្ជាប់ទំនាក់ទំនងទាំងនេះ មិនមែនជាធនាគារទេ។ សាក្សីបានអះអាងថា ពុំមានក្រដាសប្រាក់តម្កល់នៅក្នុងធនាគារ ដោយសារគណៈកម្មាធិការពាណិជ្ជកម្មធ្វើប្រតិបត្តិការតែទៅលើរូបិយវត្ថុ ប៉ុន្តែពុំបានដឹងថា តើការទូទាត់នោះជាមាស ឬជាពេជ្រ។ ពិតប្រាកដណាស់ ប្រហែលជាមានរូបិយប័ណ្ណផ្សេងធ្វើចរាចរនៅក្នុងដំណើការពាណិជ្ជកម្ម ព្រោះរូបិយប័ណ្ណ "យ័ន" មិនមានសក្តានុពលខ្លាំងក្លាទេ។ មេធាវី **បាណាបេ ណេគ្វី** បានសួរសាក្សីថាតើធនាគារពាណិជ្ជកម្មក្រៅប្រទេសគោរពតាមបទដ្ឋានអន្តរជាតិដែរឬទេ? សាក្សីបានឆ្លើយថា ប្រាកដណាស់វាមិនផ្ទុះបញ្ចាំងនឹងបទដ្ឋានអន្តរជាតិទេ ពីព្រោះគ្មានប្រព័ន្ធគណនីភាព និងពុំមានលក្ខណៈដូចជាធនាគារសព្វថ្ងៃនេះ។

សាក្សីអាចនិយាយភាសាបារាំងបាន ដូច្នេះ ពេលខ្លះគាត់ត្រូវបានស្នើឲ្យអមដំណើរគណៈប្រតិភូបរទេសទៅធ្វើទស្សនកិច្ចតាមបណ្តាខេត្តនានា ក្នុងនាមជាអ្នកបកប្រែ ប៉ុន្តែសាក្សីពុំបានបញ្ជាក់ថា នណាជាអ្នកបញ្ជាគាត់ឲ្យធ្វើការនេះទេ។ ចំពោះការផ្គត់ផ្គង់ សាក្សី **សគឹម ល្មុត** ពុំបានដឹងពីការទុកបម្រុងម្ហូបអាហារនៅក្នុងសហករណ៍នីមួយៗឡើយ ពីព្រោះគាត់និងអ្នកទទួលបន្ទុកលើកិច្ចការនេះ គឺនៅឆ្ងាយពីសហករណ៍ និងពុំមានអ្នករាយការណ៍ប្រាប់ពួកគាត់ទេ។

### ២. ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្តី

នៅថ្ងៃអង្គារ អង្គជំនុំជម្រះបានផ្តល់វេទិការកន្លះថ្ងៃដល់ក្រុមមេធាវីការពារក្តីឲ្យសួរដេញដោលសាក្សី **ស គឹមល្មុត**។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ **ខៀវ សំផន** ជាក្រុមដំបូងសួរដេញដោលសាក្សី **សគឹម ល្មុត** បន្ទាប់មក ក្រុមមេធាវីការពារក្តីលោក **នួន ជា**។ ចំណែកឯ ក្រុមមេធាវីការពារក្តីលោក **អៀង សារី** មិនបានធ្វើការសាកសួរសាក្សីទេ។

#### *ក. ការសួរដេញដោលដោយក្រុមមេធាវីការពារក្តីលោក ខៀវ សំផន*

តាមរយៈខ្សែសង្វាក់នៃការសួរដេញដោលដោយមេធាវី **គង់ សំអុន** គឺផ្តោតសំខាន់ទៅលើការមិនមានចំណងពាក់ព័ន្ធរវាងសាក្សី និងកូនក្តីខ្លួន (លោក **ខៀវ សំផន**)។ សាក្សី **សគឹម ល្មុត** បានបញ្ជាក់ថា គាត់និង

លោក **ខៀវ សំផន** មិនធ្លាប់ធ្វើការពិភាក្សាពីការចូលតស៊ូបដិវត្តន៍ ហើយគាត់ក៏មិនមានទំនាក់ទំនងជាមួយ លោក **ខៀវ សំផន** ក្រោយឆ្នាំ១៩៧០។

ចំណែកឯ តួនាទីរបស់សាក្សីនៅមុនឆ្នាំ១៩៧៤ សាក្សីបានអះអាងថា គាត់មិនមានតួនាទី ឬមុខងារអ្វី នៅក្នុងបក្សកុម្មុយនីស្ត។ សាក្សីបានចាត់ទុកខ្លួនឯងថាជា "សមានជន" ឬជាជនដែលមានចិត្តអាណិតអាសូរ ដល់បុព្វហេតុបដិវត្តន៍ សមានជនពុំមែនសុទ្ធតែជាសមាជិកសកម្មរបស់បក្សឡើយ។

តាមការលើកឡើងរបស់សាក្សី បន្ទាប់ពីចាកចេញពីសហករណ៍កៀនស្វាយទៅដល់ភ្នំពេញ **វន វ៉េត** បានជួបជំនួបជាមួយគាត់ និងប្រាប់ថា ពួកគេត្រូវការតំណាងម្នាក់ដែលមានចំណេះដឹងផ្នែកធនាគារ ដើម្បីជួប ជាមួយគណៈប្រតិភូចិនជជែកពិភាក្សាលើការងារធនាគារ។

នៅពេលធនាគារជាតិត្រូវបានបង្កើត នាពេលនោះវាពុំមានរចនាសម្ព័ន្ធអ្វីឡើយ ហើយក៏មិនមានការ ណែនាំ ឬចាត់ចែងពីថ្នាក់ដឹកនាំជាន់ខ្ពស់ណាដែរ។ សាក្សីបានដឹងមិនច្បាស់ថា នាយកគ្រប់គ្រងធនាគារ គឺឈ្មោះ **ម៉ី** ឬមានគ្រាន់តែងារ។ នៅក្នុងកិច្ចប្រជុំរវាងកម្ពុជា និងគណៈប្រតិភូចិន គាត់បានផ្តល់ជាការណែនាំ ដើម្បីជួយសម្រួលដល់ការយល់ដឹងពីវាក្យសព្ទបច្ចេកទេស។ ជាងនេះទៀត គាត់ក៏បានផ្តល់ជាអនុសាសន៍ខ្លះៗ ស្តីពីបញ្ហា នៃការនាំចេញទៅមន្ត្រីនៃគណៈកម្មាធិការពាណិជ្ជកម្ម ផ្អែកតាមទ្រឹស្តីដែលបានយល់ដឹងតិចតួច។

ឆ្លើយតបនឹងសំណួររបស់មេធាវី **គង់ សំអុន** ស្នើសុំការបញ្ជាក់ពីចម្លើយនៅដំណាក់កាលសហចៅក្រម ស៊ើបអង្កេត អំពីការ "ប៉ាន់ស្មាន" ថា "**ហែម**" គឺជាថ្នាក់លើរបស់ **អន**? សាក្សីបានឲ្យដឹងថា គាត់ធ្វើការសន្មត បែបនេះ ក្រោយពីបានឃើញឯកសារដែលដាក់បង្ហាញនៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត។ សាក្សីបន្ត សន្និដ្ឋានថា **វន វ៉េត** ស្ថិតនៅក្រោមបង្គាប់របស់ **ហែម** ព្រោះគាត់ជាប្រធាននៃប្រធានគណៈកម្មាធិការពាណិជ្ជ កម្ម។ "សាក្សីពុំមានចំណេះដឹងពីឋានានុក្រមរបស់ថ្នាក់លើទេ"។ ខណៈដែលសាក្សីមានតួនាទីជានាយករងនៃ ធនាគារពាណិជ្ជកម្មក្រៅប្រទេស "គាត់មិនមានទំនាក់ទំនងជាមួយ **ហែម**... ធនាគារក៏មិនបានរាយការណ៍ទៅ **ហែម** ហើយ **ហែម** ក៏មិនធ្លាប់ទំនាក់ទំនងមកធនាគារ និងរូបគាត់ឡើយ"។

មេធាវី **វែកកែន** បានសួរសំណួរថាតើសាក្សី **សគីម លួត** ធ្លាប់បានគិតថា **ហែម** ជាថ្នាក់លើរបស់ខ្លួន? សាក្សីបានថ្លែងថា គាត់មិនធ្លាប់បានគិតដូច្នេះទេ ប៉ុន្តែជឿជាក់ថា លោក **ខៀវ សំផន** គឺជាអ្នកដឹកនាំម្នាក់ក្នុង

ចំណោមអ្នកដឹកនាំជាន់ខ្ពស់ដទៃទៀត។ លោក **ខៀវ សំផន** គឺជាប្រមុខរដ្ឋ គាត់ឮតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ប៉ុន្តែមិនដឹងថាតើលោក **ខៀវ សំផន** ទទួលការខុសត្រូវលើធនាគារទេ។ សំណួរចុងក្រោយរបស់មេធាវី **វែកគែន** ថាតើសាក្សីចំណាំសំណេរដៃ ឬហត្ថលេខារបស់ **ខៀវ សំផន** ទេ? សាក្សីឆ្លើយតបថា គាត់ពុំបានស្គាល់ទេ។

## ខ. ការសួរដេញដោលដោយក្រុមមេធាវីការពារក្តីលោក នួន ជា

មេធាវី **សុន អារុណ** ដែលជាមេធាវីជាតិការពារក្តីលោក **នួន ជា** បានសួរដេញដោលសាក្សីដោយផ្តោតសំខាន់លើប្រវត្តិសាស្ត្រមុនឆ្នាំ១៩៧៥ ប៉ុន្តែត្រូវបានសហព្រះរាជអាជ្ញា និងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ធ្វើការជំទាស់ទៅនឹងសំណួរទាំងនោះ។ អង្គជំនុំជម្រះបានគាំទ្រសេចក្តីជំទាស់នោះ ដោយសម្អាងថា ការសួរដេញដោលរបស់មេធាវី ចាកឃ្លាតពីដែនយុត្តាធិការនៃដីកាដំណោះស្រាយ។ ប្រធានអង្គជំនុំជម្រះបានធ្វើសេចក្តីពន្យល់ដូចខាងក្រោម៖

> *អង្គហេតុដែលបានលើកឡើងដោយមេធាវី អង្គជំនុំជម្រះយល់ឃើញថា ពុំមាននៅក្នុងដីកាដំណោះស្រាយទេ ហើយក៏ពុំបានលើកឡើងនៅក្នុងសង្គ្រាម **វៀនប៉ៀនភូ** ដែលជាមួយផ្នែកនៃដីកាដំណោះស្រាយ។ លោកមេធាវីត្រូវកម្រិតអំពីសំណួររបស់ខ្លួន មុននឹងចោទសួរទៅកាន់សាក្សី។ ការលើកឡើងពីបទពិសោធន៍ផ្ទាល់ខ្លួន ពុំអនុញ្ញាតឲ្យធ្វើឡើយ បើមិនដូច្នោះលោកមេធាវីគួរធ្វើជាសាក្សីវិញ កុំដើរតួរជាភាគីនៅក្នុងសំណុំរឿង។*

ចំណែកឯ មេធាវីអន្តរជាតិ **ហ្សាស្គើ ប៉ោ** បានសួរដេញដោលពាក់ព័ន្ធនឹងឯកសារ ដែលសហចៅក្រមស៊ើបអង្កេតបានដាក់បង្ហាញនៅក្នុងដំណាក់កាលស៊ើបសួរ។ មេធាវី **ហ្សាស្គើ ប៉ោ** បានសួរសំណួរថាតើឯកសារទាំងនេះបានជួយសាក្សីក្នុងការយល់ដឹងអំពីរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ? សាក្សីបានឆ្លើយថា ឯកសារទាំងនោះពិតជាបានជួយរំឭកដល់ការចងចាំ ប៉ុន្តែ បានត្រឹមតែក្នុងកម្រិតមួយប៉ុណ្ណោះ ព្រោះឯកសារទាំងនោះពុំបានផ្តល់ព័ត៌មានលម្អិតទេ។ មេធាវី **ហ្សាស្គើ ប៉ោ** បានបន្តសំណួរដោយឲ្យសាក្សី **សតឹម ល្មុត** ធ្វើការបញ្ជាក់លើមូលដ្ឋានមួយចំនួន ដែលកម្ពុជាពុំបានធ្វើការនាំចេញស្រូវ? សាក្សីបានឲ្យដឹងថា ករណីនេះហួសពីសមត្ថភាពយល់ដឹងរបស់គាត់ ហើយអាចនាំទៅរកការប៉ាន់ស្មាន ព្រោះពុំមានឯកសារ ឬស្ថិតិណា

មួយបានបញ្ជាក់ឡើយ។ ទោះបីជាពុំទទួលបានចម្លើយ ក៏មេធាវី **ហ្សាស្តេ ប៉ៅ** នៅតែបន្តជជីកដេញដោលពាក់ព័ន្ធនឹងឯកសារទាំងនោះ ដោយលើកបង្ហាញនូវឯកសារជាក់លាក់មួយ សាក្សីនៅតែអះអាងថា គាត់ពុំធ្លាប់បានឃើញឯកសារនោះ។ ហេតុនេះ ប្រធានអង្គជំនុំជម្រះបានណែនាំឲ្យមេធាវី **ហ្សាស្តេ ប៉ៅ** បន្តសំណួរដោយពុំចាំបាច់យោងលើឯកសារ។ បន្ទាប់ពីស្តាប់នូវសេចក្តីសម្រេច មេធាវី **ហ្សាស្តេ ប៉ៅ** បានសម្តែងការមិនពេញចិត្ត និងបានបញ្ឈប់ការសួរដេញដោលលើសាក្សីជាបន្តទៀត។

**៣. ការសួរដេញដោលសាក្សីដោយចៅក្រមក្រុមប្រឹក្សា**

ចៅក្រម **ឡាវែន៍** ក៏បានសួរដេញដោលសាក្សី ដោយចាប់ផ្តើមសំណួរថា តើមានហេតុផលណាដែលថា លោក **ខៀវ សំផន** គឺជាមនុស្សមានឈ្មោះហៅក្រៅ "**ហែម**"? សាក្សីបានឆ្លើយថា នេះគឺជាករណីស្មុគស្មាញ ដោយសារតែមានបុគ្គលជាច្រើនអាចមានឈ្មោះ "**ហែម**"។ នាសម័យកម្ពុជាប្រជាធិបតេយ្យ គាត់ពុំបានស្គាល់បុគ្គលនោះទេ ប៉ុន្តែនាពេលបច្ចុប្បន្ន ឈ្មោះ "**ហែម**" ត្រូវបានស្គាល់ថាជាលោក **ខៀវ សំផន** ទោះបីជាពុំមានឯកសារបញ្ជាក់។

**ខ. សក្ខីកម្មរបស់សាក្សី សៅ សារុន**

សាក្សី **សៅ សារុន** មានអាយុ ៨០ឆ្នាំ តាមរយៈសហព្រះរាជអាជ្ញាបានបង្ហាញថា នៅក្នុង "ជីវប្រវត្តិចូលរួមបដិវត្តន៍" សាក្សីមានឈ្មោះហៅក្រៅ "**ប៉ែ**" ប៉ុន្តែសាក្សីអះអាងថា គាត់មានឈ្មោះតែមួយគត់ គឺ **សៅ សារុន**។ សាក្សីមានបញ្ហាកែវភ្នែក ដែលធ្វើឲ្យគាត់ពិបាកក្នុងការកំណត់ពណ៌ ជាពិសេស ភ្លើងក្រហមម៉ែក្រូហ្វូនសម្លេង ដែលបញ្ជាក់ពីភាពមានដំណើរការ។ ជាងនេះ សាក្សី **សៅ សារុន** បានឲ្យដឹងថា ការចងចាំរបស់គាត់មានការខូចខាត និងបាត់បង់ដោយសារតែជម្ងឺ ដូចនេះ ដើម្បីរំឭកការចងចាំត្រូវដាក់បង្ហាញឯកសារ ដែលបានធ្វើដោយចៅក្រមស៊ើបអង្កេត។

**១. តួនាទីរបស់សាក្សីនៅមុនពេល និងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ**

សាក្សីបានរៀបរាប់ថា គាត់បានចូលរួមបដិវត្តន៍នៅក្នុងឆ្នាំ១៩៥៤។ នាពេលនោះ គាត់ទទួលបានវគ្គបណ្តុះបណ្តាលនៅភូមិ ដែលមានរយៈពេល ២ទៅ៣ថ្ងៃ គាត់មានការយល់ដឹងតិចតួចចំពោះមាគ៌ានយោបាយ

របស់បក្ស។ តួនាទីរបស់សាក្សី គឺអប់រំប្រជាពលរដ្ឋ អំពីគោលការណ៍បដិវត្តន៍ ដូចជា *"ការជួយខ្លួនឯង"*។ បន្ទាប់មក នៅឆ្នាំ១៩៧០ សាក្សីបានក្លាយជាអនុលេខាធិការឃុំនៅខេត្តមណ្ឌលគីរី និងទទួលខុសត្រូវលើកិច្ចការសេដ្ឋកិច្ច ខណៈនោះសាក្សីក៏ជាសមាជិកកងឈ្លបប្រចាំភូមិផងដែរ។

ពីឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧៨ សាក្សីត្រូវបានតែងតាំងជាលេខាធិការស្រុកពេជ្រាដា។ ភារៈកិច្ចរបស់គាត់ គឺគ្រប់គ្រងប្រជាពលរដ្ឋ និងធានាថា ពួកគេមានអាហារហូបចុកគ្រប់គ្រាន់ និងមានលំនៅឋានសមរម្យ។ គ្រានោះ សាក្សីមានអំណាចក្នុងការចាត់តាំងលេខាធិការឃុំនៅក្នុងស្រុកដែលខ្លួនកាន់កាប់ ប៉ុន្តែក្នុងនាមជាលេខាស្រុក គាត់ពុំមានអំណាចក្នុងការចាប់ចងបុគ្គលណាម្នាក់ឡើយ។ សាក្សីក៏មើលការខុសត្រូវលើការងារសេដ្ឋកិច្ច ប្រចាំស្រុកពេជ្រាដា និងស្រុកអូររាំង និងនៅឆ្នាំ១៩៧៤ សាក្សីជាសមាជិកនៅក្នុង "គណៈកម្មាធិការបរទេស"។ សាក្សីអាចនិយាយភាសាចារាយយ៉ាងផ្ទាត់ជំនាញ ដែលជាហេតុនាំឲ្យគាត់ត្រូវបានតែងតាំង និងបំពេញមុខងារក្នុងការទំនាក់ទំនងជាមួយប្រជាពលរដ្ឋនៅក្នុងតំបន់ដែលនិយាយភាសាដូចគ្នា។ នៅឆ្នាំ១៩៧៥ សាក្សីបានក្លាយជាសមាជិកថ្នាក់តំបន់ ទទួលបន្ទុកលើការងារសុខាភិបាល ព្រមទាំងទទួលខុសត្រូវលើមន្ទីរពេទ្យ និងផ្ទះសម្ភពនៅក្នុងតំបន់។ ភារៈកិច្ចនេះ គឺធ្វើយ៉ាងណាធានាអនាម័យមន្ទីរពេទ្យឲ្យស្អាតជានិច្ច។

បន្ទាប់ពីការស្លាប់របស់ **តា ឡាំង** (ជាលេខាតំបន់ និងជាថ្នាក់លើរបស់គាត់) នៅឆ្នាំ១៩៧៨ **ប៉ុល ពត** បានតែងតាំងគាត់ជាលេខាតំបន់ជំនួស។ នាពេលនោះ សាក្សីបានព្យាយាមប្រកែកបដិសេធពុំទទួលយកការងារនោះ ប៉ុន្តែ **ប៉ុល ពត** ពុំយល់ព្រមឡើយ។ ជាលទ្ធផល សាក្សី **សៅ សារុន** បានក្លាយជាលេខាតំបន់បានរយៈពេល ២ខែ មុនការចូលមកដល់នៃកងទ័ពវៀតណាមនៅឆ្នាំ១៩៧៩។

### ២. រចនាសម្ព័ន្ធរដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ

ដំបូងឡើយ សាក្សីមានតួនាទីទទួលខុសត្រូវត្រឹមតែថ្នាក់ស្រុក បន្ទាប់មកថ្នាក់តំបន់ ដូច្នេះ សាក្សីអាចរៀបរាប់បានយ៉ាងល្អិតល្អន់ ចំពោះរចនាសម្ព័ន្ធរដ្ឋបាលស្ថិតក្នុងតំបន់ដែលខ្លួនកាន់កាប់ "តំបន់១០៥"។ សាក្សី **សៅ សារុន** បានឲ្យដឹងថា "តំបន់១០៥" និង "ខេត្តមណ្ឌលគីរី" គឺជាតំបន់តែមួយ។ នៅតំបន់១០៥ គឺមាន ៥ស្រុក រួមមានដូចជា ស្រុកកោះញែក ស្រុកសែនមនោរម្យ ស្រុកពេជ្រាដា ស្រុកអូររាំង និងស្រុកកែវសីម៉ា។ ចំណែកឯនៅស្រុកពេជ្រាដាមាន ៤ឃុំ គឺ ឃុំក្រាំងតេះ ឃុំប៊ូស្រា ឃុំទោស្វាយ និងឃុំកៅក្តៃ។ ស្រុកពេជ្រដា

និងស្រុកកែវសីម៉ា មានព្រំប្រទល់ជាប់ទល់ដែនវៀតណាម។ ចំពោះការរាយការណ៍ លេខាឃុំត្រូវរាយការណ៍ទៅលេខាស្រុក ហើយលេខាថ្នាក់ស្រុកត្រូវរាយការណ៍បន្តទៅលេខាថ្នាក់តំបន់។ មន្ត្រីនៃឃុំនីមួយៗអាចក្លាយជាសមាជិកបក្ស។ នៅក្នុងស្រុកពេជ្រាដា ប្រជាពលរដ្ឋមានប្រមាណជា ៣,៤០០នាក់។

សាក្សី **សៅ សារុន** បានបន្តថា នៅក្នុងតំបន់នីមួយៗ គឺមានមន្ទីរសន្តិសុខ ឬមន្ទីរកែប្រែដាច់ដោយឡែក។ នៅក្នុងតំបន់១០៥ ក៏មានមន្ទីរពាណិជ្ជកម្ម ដែលស្គាល់ថាជា មន្ទីរ ក-១៦។ នៅឆ្នាំ១៩៧៥ កងពល៩២០ បានបោះទីតាំងនៅស្រុកកោះញែក ខេត្តមណ្ឌលគីរី ហើយក៏មានទីតាំងនៅស្រុកដទៃទៀតដែរ។

សាក្សីបានផ្តល់សក្ខីកម្មថា នៅតំបន់១០៥ មានមន្ទីរពេទ្យតំបន់មួយ ចំណែកឯនៅថ្នាក់ស្រុក មានមន្ទីរពេទ្យស្រុកតូចៗមួយចំនួន។ ថ្នាំសង្កូវ និងគ្រឿងឧបករណ៍ព្យាបាលសម្រាប់មន្ទីរពេទ្យទទួលបានពីទីក្រុងភ្នំពេញ នាពេលនោះ សម្ភារៈផ្គត់ផ្គង់គឺទទួលបានគ្រប់គ្រាន់។ ជម្ងឺដែលកើតច្រើនជាងគេ គឺជម្ងឺគ្រុនចាញ់ និងជម្ងឺរបេង។

### ៣. ការប្រាស្រ័យទាក់ទងជាមួយថ្នាក់លើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

សាក្សីបានឲ្យដឹងថា គាត់បានចូលរួមប្រជុំជាច្រើនលើកជាមួយថ្នាក់ដឹកនាំកំពូលៗនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមមាន កិច្ចប្រជុំពីរនៅខេត្តកំពង់ធំ។ កិច្ចប្រជុំលើកទី១ រៀបចំឡើងនៅចន្លោះឆ្នាំ១៩៧០-១៩៧៥។ សាក្សីពុំបានបញ្ជាក់ពីឆ្នាំឲ្យបានជាក់លាក់ទេ ប៉ុន្តែនៅពេលសហព្រះរាជអាជ្ញាលើកឡើងថា កិច្ចប្រជុំនោះរៀបចំនៅឆ្នាំ១៩៧១ សាក្សីបានធ្វើការឯកភាពចំពោះការលើកឡើងនោះ។ ក្នុងកំឡុងកិច្ចប្រជុំនោះ **ប៉ុល ពត** បានធ្វើបទបង្ហាញមួយ អំពីការប្រឆាំងតបតនឹងពួកចក្រព័ត្តអាមេរិកាំង។ ចំណែកឯកិច្ចប្រជុំលើកទី២ គឺធ្វើឡើងនៅ ឆ្នាំ១៩៧២ នាពេលនោះ សាក្សីបានជួបលោក **នួន ជា** និង **ប៉ុល ពត** ដែលអ្នកទាំងពីរមានវត្តមាននៅក្នុងកិច្ចប្រជុំ ប៉ុន្តែពុំបានឃើញលោក **ខៀវ សំផន** ទេ។ សាក្សីពុំបានដឹងអំពីតួនាទីជាក់លាក់របស់ **នួន ជា** នៅក្នុងកិច្ចប្រជុំនោះ គាត់បានធ្វើបទបង្ហាញពីការប្រឆាំងជាមួយពួកចក្រព័ត្តអាមេរិកាំង។

បន្ទាប់មកប្រហែល ១ខែ នៅឆ្នាំ១៩៧៥ “ទីក្រុងភ្នំពេញត្រូវរំដោះ” នាពេលនោះ សាក្សីបានចូលរួមកិច្ចប្រជុំមួយមានរយៈពេល ៣ថ្ងៃ ធ្វើនៅសាលារៀនមិត្តភាពសហភាពសូវៀត-កម្ពុជា ដែលមានតំណាង

ប្រចាំភូមិភាគ និងតំណាងកងពលយោធានានា បានចូលរួមយ៉ាងច្រើនកុះករ។ លោក **នួន ជា** បានធ្វើបទបង្ហាញអំពីការកសាងប្រទេសឡើងវិញ ការបិទទីផ្សារ និងដំណើរការបើកទីផ្សារឡើងវិញនាពេលអានាគត។ ចំណែក **ប៉ុល ពត** បានធ្វើបទបង្ហាញពាក់ព័ន្ធនឹងគំរោងកសាងប្រព័ន្ធធារាសាស្ត្រ និងការជីកព្រែកជីកប្រឡាយទូទាំងផ្ទៃប្រទេស ដើម្បីបង្កភាពងាយស្រួលដល់ការបង្កបង្កើនដំណាំស្រូវ។

ដូចបានរៀបរាប់ខាងលើ សាក្សី **សៅ សារុន** បានជួបផ្ទាល់ជាមួយ **ប៉ុល ពត** នៅឆ្នាំ១៩៧៨ នៅពេលដែលគាត់ត្រូវតែងតាំងបន្តវេនពី **តា ឡាំង** ជាលេខាតំបន់។ នៅក្នុងជំនួបនោះ **សុន សេន** និង **នួន ជា** ក៏មានវត្តមានផងដែរ ដែលធ្វើនៅមន្ទីរមួយនៅក្រោយព្រះបរមរាជវាំង។ ក្រោយមកប្រមាណជា ២ទៅ៣ខែ សាក្សីត្រូវបានអញ្ជើញឲ្យឡើងមកទីក្រុងភ្នំពេញជាមួយសមមិត្ត ៥រូបទៀត ចូលរួមកិច្ចប្រជុំមួយនៅមន្ទីរ ដែលមានទីតាំងក្រោយព្រះបរមរាជវាំង។ អ្នកចូលរួមភាគច្រើនសុទ្ធតែជាថ្នាក់ដឹកនាំជាន់ខ្ពស់យោធាមកពីតំបន់ ១០៥ ឬកងពល៩២០។ សាក្សី **សៅ សារុន** បន្តថា **ប៉ុល ពត** - **សុន សេន** - **នួន ជា** និង **ខៀវ សំផន** ក៏មានវត្តមាននាពេលនោះ ដោយប្រជុំពិភាក្សាពីបញ្ហាពាក់ព័ន្ធ *"ការរៀបចំកងកម្លាំងប្រដាប់អាវុធ"* - *គោលការណ៍ជួយខ្លួនឯង* - និង *ការពង្រឹងព្រំដែន*។ នាឱកាសនោះ សាក្សីបានជួបជំនួបពិភាក្សាការងារសេដ្ឋកិច្ចជាមួយ **ខៀវ សំផន** និងបានស្នើសុំសម្ភារៈផ្គត់ផ្គង់មួយចំនួន រួមមាន អំបិល និងសម្លៀកបំពាក់សម្រាប់ប្រជាពលរដ្ឋ។ ជាងនេះទៀត សាក្សីបានប្រាប់ **ខៀវ សំផន** អំពីកង្វះខាតនានានៅតំបន់១០៥ ព្រោះគាត់ យល់ថា **ខៀវ សំផន** គឺជាប្រមុខរដ្ឋនាសម័យនោះ។

សាក្សីបានចូលរួមវគ្គបណ្តុះបណ្តាលនយោបាយចំនួន ២លើក នៅទីក្រុងភ្នំពេញ ពីចន្លោះឆ្នាំ១៩៧៥-១៩៧៨ ៖ លើកទី១ នៅបូរីកីឡា និងមួយលើកទៀត នៅទីកន្លែងមួយ ដែលមានទីតាំងនៅចន្លោះរវាងបូរីកីឡា និងមហាវិថីសហព័ន្ធរូស្ស៊ី[2]។ វគ្គបណ្តុះបណ្តាលនីមួយៗប្រព្រឹត្តទៅមានរយៈពេល ១២ថ្ងៃ។ នៅក្នុងវគ្គបណ្តុះបណ្តាល លោក **នួន ជា** បានផ្តល់ការណែនាំអំពីបញ្ហាសេដ្ឋកិច្ច និងពិភាក្សាអំពីការដឹកនាំ ព្រមទាំងការជម្រុញលើកទឹកចិត្តប្រជាពលរដ្ឋឲ្យធ្វើកសិកម្ម ដើម្បីបញ្ចៀសការអត់ឃ្លាន។ សាក្សី **សៅ សារុន** បានបន្ថែមថា **ប៉ុល ពត** - **ខៀវ សំផន** - **អៀង សារី** និង **អៀង ធីរិទ្ធ** ក៏ចូលរួមនៅកិច្ចប្រជុំនោះដែរ។

សាក្សីផ្តល់សក្ខីកម្មថា គាត់បានទំនក់ទំនងជាមួយថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈ

ការឆ្លើយឆ្លងតាមសារទូរលេខ យ៉ាងហោចណាស់ ២សប្តាហ៍ម្តង។ សាក្សីបានសរសេរសំបុត្រដោយដៃ និង ប្រគល់ឱ្យអ្នកទទួលបន្ទុកផ្ញើសារទូរលេខ វាយឡើងវិញ និងបញ្ជូនចេញ។ ចំពោះការឆ្លើយតប សាក្សីទទួលពី ប្រភពនានា ដូចជា មន្ទីរ៨៧០ - **ប៉ុល ពត** - និង **នួន ជា** ជាដើម។ មន្ទីរ ៨៧០ គឺសំដៅទៅលើគណៈមជ្ឈិម ដែលរួមមាន **ប៉ុល ពត** - **នួន ជា** - **ខៀវ សំផន** - **សុន សេន** - និង **តាម៉ុក**។

នៅពេលតំណាងសហព្រះរាជអាជ្ញា **លីសាក់** សួរបញ្ជាក់សាក្សីថា "...នៅពេលលោកបញ្ជូនសារទូរលេខទៅមន្ទីរ ៨៧០ តើលោកផ្ញើជូនចំពោះបុគ្គលណាមួយ?" សាក្សីបានឆ្លើយថា "មន្ទីរ ៨៧០ គឺជាមន្ទីររបស់ **ប៉ុល ពត**"។

តំណាងសហព្រះរាជអាជ្ញាបានយោងទៅលើសារទូរលេខជាក់លាក់ចំនួន ៣ច្បាប់ ដែលសារទូរលេខទាំងនេះ គឺមានទំនាក់ទំនងទៅវិញទៅមករវាងសាក្សី និង **ប៉ុល ពត**។ នៅក្នុងសារទូរលេខទី១ សាក្សីបានស្នើសុំការណែនាំពី **ប៉ុល ពត** ចំពោះឧប្បទ្ទវហេតុផ្ទុះទូកផ្ទុកប្រេងសាំងប្រេងម៉ាស៊ុត។ សារទូរលេខទី២ គឺការស្នើសុំការណែនាំពី **ប៉ុល ពត** ពាក់ព័ន្ធនឹងការបំពាក់អាវុធដល់ប្រជាពលរដ្ឋឡើងវិញ (យោងលើផែនការចាស់ដែលដកអាវុធពីប្រជាពលរដ្ឋ)។ សារទូរលេខទី៣ គឺជាសំណើសុំការណែនាំតាមដានលើឈ្មោះ **សុទ្ធ** ដែលជាប្រធានរោងចក្រផលិតគ្រឿងសម្ភារៈ (បុគ្គលនេះត្រូវបានចោទប្រកាន់ថា ប្រព្រឹត្តអំពើអសីលធម៌លើស្ត្រីភេទ ទោះបីជាខ្លួនបានរៀបការហើយ)។

### ៤. គោលនយោបាយបក្ស

មុនឆ្នាំ១៩៧៥ ក្រុមប្រវាសដៃត្រូវបានស្គាល់ថា *"ក្រុមសាមគ្គី"* នៅក្នុងតំបន់។ សាក្សីបាន ឱ្យដឹងថា "ក្រុមសាមគ្គី" គឺជា "ក្រុមធ្វើការងារប្រវាសដៃ"។ ទោះបីជា ក្រុមសាមគ្គីត្រូវបាន ចាប់ផ្តើមតាំងពីឆ្នាំ១៩៧១-១៩៧៥ក៏ដោយ ក៏ប្រជាជននៅហូបចុកដាច់ដោយឡែក និងមានកម្មសិទ្ធិផ្ទាល់ខ្លួន។ ចំណែកឯ សហករណ៍ត្រូវបានបង្កើតឡើងនៅខេត្តមណ្ឌលគីរីនៅប្រហែលជាឆ្នាំ១៩៧៧។ ភាពខុសគ្នានៃប្រព័ន្ធទាំងពីរ គឺថា ប្រជាពលរដ្ឋនៅក្នុងសហករណ៍ត្រូវហូបរួម ដែលមានចំនួនប្រមាណជា ២០ ទៅ ៣០នាក់។ ថ្នាក់តំបន់ជាអ្នកចេញគោលការណ៍ណែនាំ និងការកំណត់នានានៅក្នុងសហករណ៍។

នៅក្នុងកិច្ចប្រជុំរយៈពេល ៣ថ្ងៃ ដែលសាក្សី **សៅ សារុន** បានចូលរួមនៅទីក្រុងនៅឆ្នាំ១៩៧៥ អ្នកចូលរួមបានពិភាក្សាអំពីបញ្ហាលុបបំបាត់ទ្រព្យសម្បត្តិឯកជន។ ទ្រព្យសម្បត្តិទាំងនេះ រួមបញ្ចូលទាំងសត្វពាហនៈ ត្រូវដាក់ឲ្យប្រើប្រាស់រួមនៅក្នុងសហករណ៍។ ចំពោះប្រាក់កាកវិញ ពុំត្រូវបានប្រមូល ឬដាក់រួមទេនៅក្នុងតំបន់របស់គាត់។ ទីផ្សារក៏ពុំមានដំណើរការនៅតំបន់របស់គាត់ គឺតាំងពីមុនឆ្នាំ១៩៧៥ ដោយសារតែការទម្លាក់គ្រាប់បែកពីចក្រព័ត្តអាមេរិកាំង ដូច្នេះនៅពេលកាន់កាប់ទីក្រុងភ្នំពេញ ពុំមានផ្សារដែលត្រូវបិទទេ។ សាក្សីបន្ថែមថា ប្រជាពលរដ្ឋនៅខេត្តមណ្ឌលគីរី ពុំមានបែងចែកជាក្រុមតូចៗ និងទទួលបានសិទ្ធិផ្សេងគ្នាទេ។

សាក្សី **សៅ សារុន** ក៏បានបន្តសក្ខីកម្មថា **ប៉ុល ពត** បានផ្តល់ការណែនាំអំពីការរៀបអាពាហ៍ពិពាហ៍នៅក្នុងកិច្ចប្រជុំរយៈពេល ៣ថ្ងៃនោះដែរ។ ការប្រារព្ធពិធីរៀបអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន គឺមិនថាមានលក្ខណៈ មួយគូ ឬច្រើនគូ។ ការអនុញ្ញាតពីឪពុកម្តាយ ការយល់ព្រមពីភាគីកូនកំលោះកូនក្រមុំ ព្រមទាំងការអនុញ្ញាតពីអង្គការ គឺតម្រូវយ៉ាងដាចខាតមុននឹងរៀបអាពាហ៍ពិពាហ៍។ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍គូស្រករត្រូវប្តេជ្ញាថា ស្រឡាញ់គ្នាទៅវិញទៅមក និងរស់នៅជាមួយគ្នាដល់ចាស់សក់ស្កូវ។ “អាពាហ៍ពិពាហ៍” គឺជាការអនុញ្ញាតឲ្យរួមរស់នៅជាមួយគ្នា។

ចំពោះសាសនា សាក្សីបានឲ្យដឹងថា សាសនាពុំត្រូវបានហាមឃាត់ទេនៅខេត្តមណ្ឌលគីរី ក៏ប៉ុន្តែប្រជាពលរដ្ឋពុំអនុញ្ញាតឲ្យធ្វើពិធីធំដុំឡើយ។ អង្គការតម្រូវឲ្យប្រជាពលរដ្ឋយកចិត្តទុកដាក់លើការធ្វើកសិកម្មជាជាងការប្រារព្ធពិធីជំនឿសាសនា។ នៅក្នុងទឹកដីខេត្តមណ្ឌលគីរី វត្តអារ៉ាមត្រូវបានសាងសងឡើងនៅឆ្នាំ ១៩៦៣ មានវត្តចំនួន៣ ប៉ុន្តែវត្តទាំងនេះត្រូវបានបិទទាំងស្រុងក្រោយឆ្នាំ១៩៧៥ ខែមេសា។ ការទម្លាក់គ្រាប់បែកដោយពួកចក្រព័ត្តអាមេរិក ក៏ជាឬសគល់ធ្វើឲ្យវត្តអារ៉ាមត្រូវបានបិទ ព្រោះវាមិនត្រឹមតែបំផ្លាញផ្ទះសម្បែង និងវត្តអារ៉ាម ប៉ុន្តែក៏បានធ្វើឲ្យព្រះសង្ឃរត់ភៀសខ្លួនចេញពីតំបន់នោះអស់។ ចាប់តាំងពីឆ្នាំ១៩៧០មក គ្រាប់បែកត្រូវបានទម្លាក់ឥតឈប់ឥតឈរ មិនថាថ្ងៃ ឬយប់ឡើយ។ ទោះបីជាយ៉ាងណា សាក្សីពុំបានដឹងពីមូលហេតុដែលនាំឲ្យវត្តអារ៉ាមពុំបានសាងសង់ឡើងវិញ។ ចំពោះប្រជាជនដែលគោរព និងមានជំនឿតាមបែបទំនៀមទម្លាប់ជនជាតិដើមភាគតិច ដូចជា ការបូជាយ៉ាញ់ អ្នកទាំងនោះត្រូវបានណែនាំឲ្យកាត់បន្ថយនូវសំណែនក្នុងការធ្វើពិធី ព្រោះស្ថានភាពសេដ្ឋកិច្ចកំពុងជួបប្រទះបញ្ហាលំបាក។

កិច្ចប្រជុំស្វ័យទិទៀន គឺមានធ្វើនៅក្នុងតំបន់១០៥។ នៅថ្នាក់តំបន់ កិច្ចប្រជុំប្រព្រឹត្តទៅរៀងរាល់ ៦ខែម្តង មានអ្នកចូលរួមប្រមាណជាង ៨ ទៅ ១០នាក់ ។ ចំពោះថ្នាក់ស្រុក លេខាស្រុក និងអនុលេខាស្រុក បានចូលរួមនៅក្នុងកិច្ចប្រជុំស្វ័យទិទៀននោះ។ នៅក្នុងកិច្ចប្រជុំស្វ័យទិទៀន អ្នកចូលរួមត្រូវតែបង្ហាញពីភាពល្អស្អាត និងភាពស្អាតស្អំរបស់ខ្លួនទៅប្រជាជន និងពុំឲ្យ "ជះឥទ្ធិពលអាក្រក់ទៅប្រជាជនឡើយ"។ សាក្សីបន្តថា សិក្ខាកាមត្រូវបានរិះគន់ ប៉ុន្តែពុំមានដាក់ទោសពិន័យឡើយ។

សាក្សីបន្ថែមថា នៅថ្ងៃទី១៧ មេសា ១៩៧៥ គាត់នៅស្រុកពេជ្រាដា និងពុំបានដឹងពីផែនការ និងស្ថានភាពលម្អិតពីការជម្លៀសប្រជាជនចេញពីក្រុង និងទីប្រជុំជនឡើយ។

### ៥. ការសម្លាប់ និងការបាត់ខ្លួន

សាក្សី **សៅ សារុន** បានបញ្ជាក់ថា លេខាធិការស្រុកគ្រប់រូប (លើកលែងរូបគាត់) បានស្លាប់បាត់បង់ជីវិត ឬបាត់ខ្លួន ឬក៏ត្រូវចាប់ខ្លួន នាឆ្នាំ១៩៧៧។ សាក្សី **សៅ សារុន** បានបន្តថា គាត់ពុំបានដឹងពីមូលហេតុដែលនាំឲ្យកើតករណីនេះឡើយ។ ឈ្មោះ **ម៉ា ឡា** ដែលជាលេខាស្រុកពេជ្រាដាមុន ត្រូវបានចាប់ខ្លួនទៅមន្ទីរតំបន់ និងបាត់ដំណឹងរហូតចាប់ពីឆ្នាំ១៩៧៧។ ចំណែកឯឈ្មោះ **ម៉ី** ដែលជាសមាជិករបស់គណៈតំបន់ក៏ត្រូវបានបាត់ខ្លួននៅឆ្នាំ១៩៧៧។ ឈ្មោះ **ស្វាយ** ដែលជាលេខាស្រុក ត្រូវបានចោទប្រកាន់ថា បានបាញ់សម្លាប់មនុស្ស ២នាក់ មុននឹងចងកខ្លួនឯងនៅវាលស្រែ។ ចំណែកក្រោយមកមានជនរងគ្រោះឈ្មោះ **ឃី** ដែលជាលេខាស្រុកអូរាំង និងឈ្មោះ **ជន** ដែលជាសមាជិកគណៈស្រុកពេជ្រាដា អ្នកទាំងពីរត្រូវជាបងប្អូនសាច់ថ្លៃរបស់សាក្សី **សៅ សារុន** ។ ឧប្បទ្ទេវហេតុកើតឡើងចំពោះ **តាឡាំង** (លេខាតំបន់ចាស់) គាត់ត្រូវឈ្មោះ **ខាំបុណ្យ** (អ្នកមើលការខុសត្រូវមន្ទីរ ក-១៦) ចាក់សម្លាប់នឹងគ្រឿងបន្លាស់រថយន្ត មុនពេលឈ្មោះនេះបាញ់សម្លាប់ខ្លួនឯង។

ដូចមាននៅក្នុងសារទូរលេខ គឺសាក្សី **សៅ សារុន** បានរាយការណ៍ទៅ **ប៉ុល ពត** នៅពេលឧប្បទ្ទេវហេតុឆេះទូកដឹកប្រេងសាំងប្រេងម៉ាស៊ូត។ មនុស្ស ៣នាក់ ធ្វើការនៅលើទូកនោះ និងមានម្នាក់ឈ្មោះ **លីន** ។ ឈ្មោះ **លីន** គឺមាននៅក្នុងបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ ដែលត្រូវបានដាក់បង្ហាញដល់សាក្សី ក៏ប៉ុន្តែសាក្សីបានអះអាងថា **លីន** នៅរស់មានជីវិតរហូតសព្វថ្ងៃ។

សាក្សីផ្តល់សក្ខីកម្មថា គាត់ពុំមានសិទ្ធិអំណាចសម្រេចដោះលែងអ្នកទោស ដែលចោទ ប្រកាន់ថាក្បត់នឹងបក្សទេ (ឧទាៈ ការចោទប្រកាន់ចូលដៃជាមួយពួកឈ្លានពាន)។ គាត់ចាំការណែនាំពីថ្នាក់លើក្នុងការដោះលែងជនសង្ស័យទាំងនោះ ទើបអាចធ្វើបាន។ សាក្សីបានថ្លែងថា មានមនុស្ស ២ទៅ៣នាក់ ជាប់ឃុំនៅពេលគាត់ក្លាយជាលេខាតំបន់។ សាក្សីបានសួរចម្លើយ និងដោះលែងពួកគេ បន្ទាប់ពីមានបញ្ជាពីថ្នាក់ លើ។ "ពុំមាននរណាម្នាក់ ដែលត្រូវបានសួរម្លើយ ហើយកម្ទេចនោះទេ"។

**គ. សក្ខីកម្មរបស់ ខឹក ងន**

សាក្សី **ខឹម ងន** គឺជាសាក្សីចុងក្រោយ ដែលមកផ្តល់សក្ខីកម្មនាសប្តាហ៍នេះ។ សាក្សី **ខឹម ងន** គឺជាអតីតយុទ្ធជនអាយុ ៥៧ឆ្នាំ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីគឺជានីរសារប្រចាំខេត្តតាកែវ ក្រោយមក គាត់ត្រូវបានបញ្ជូនទៅទីក្រុងភ្នំពេញ ធ្វើការនៅក្រសួងការបរទេស និងទទួលបន្ទុកជាអ្នកអមដំណើរភ្ញៀវការបរទេស។ សាក្សី **ខឹម ងន** បានថ្លែងថា គាត់ពុំចេះអក្សរទេ និងជួបការពិបាកក្នុងការចងចាំកាលបរិច្ឆេទ។

**១. ការចូលរួមបដិវត្តន៍ និងទំនួលខុសត្រូវមុនពេលបក្សកុម្មុយនីស្តកម្ពុជាកាន់អំណាច**

តំណាងសហព្រះរាជអាជ្ញា **ច័ន្ទ តារាស្មី** បានចាប់ផ្តើមការសួរដេញដោលសាក្សីពាក់ព័ន្ធនឹងជីវប្រវត្តិផ្ទាល់ខ្លួន និងការជ្រើសរើសចូលរួមចលនាបដិវត្តន៍។ សាក្សីបានរៀបរាប់ថា គាត់បានចាកចេញពីផ្ទះទៅចូលរួមចលនាបដិវត្តន៍នៅអាយុ ១៥ ឬ ១៦ឆ្នាំ។ ការចូលរួមបដិវត្តន៍ គឺតាមរយៈមិត្តភក្តិ និងដោយការស្ម័គ្រចិត្តចូលបម្រើកងទ័ព គាត់មិនបានយល់ដឹងពីហេតុផលនៃចលនានេះទេ។ ក្នុងនាមជាទាហានមួយរូប សាក្សីត្រូវបានចាត់ឲ្យធ្វើការនៅឃុំស្រុកនានានៅខេត្តតាកែវ។ នៅពេលគាត់ក្លាយជានីរសារនៅខេត្តតាកែវ គាត់មិនមានទំនាក់ទំនងជាមួយថ្នាក់លើណាម្នាក់ទេ។ គាត់ត្រូវបានណែនាំឲ្យបញ្ជូនសារឲ្យទាន់ពេលវេលា។ នៅពេលមានសំណួរ ថាតើមានទណ្ឌកម្មណាក្នុងករណីខកខានពុំអនុវត្តតាមការណែនាំ? សាក្សីបានឆ្លើយតបថា *"ពួកគេហៅខ្ញុំទៅរៀនសូត្រឡើងវិញ។ មានពេលខ្លះ ពួកគេបានព្យួរការងារខ្ញុំ ១ថ្ងៃ ដែលកំឡុងពេលនោះ ពួកគេអប់រំខ្ញុំឡើងវិញ"*។

ចំពោះការអប់រំផ្នែកនយោបាយ សាក្សីបានឲ្យដឹងថា យុទ្ធជនត្រូវបានអប់រំអំពី "សីលធម៌ និងឥរិយាបថផ្សេងៗ"។ សាក្សីពុំត្រូវបានអនុញ្ញាតឲ្យទៅលែងផ្ទះ និងគ្រួសាររបស់ខ្លួន ឬប្រារព្ធពិធីសាសនានោះទេ។

សាក្សីចង់ចាកចេញពីចលនានេះ ដោយសារការរឹតត្បិតច្រើនពេក ប៉ុន្តែគាត់មិនហ៊ានធ្វើដូច្នេះ ព្រោះខ្លាចគ្រួសារអាចមាន "បញ្ហា"។

សាក្សី **ខឹម ងន** បានឲ្យដឹងថា ការជម្លៀសប្រជាជននៅទីរួមខេត្តតាកែវ គឺធ្វើមុនឆ្នាំ១៩៧៥។ ការជម្លៀសនេះ មានទ្រង់ទ្រាយតូច ដែលស្ទើរតែពុំអាចសម្គាល់ថាជាការជម្លៀសប្រជាជន។

### ២. តួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ប្រហែលជាកន្លះខែបន្ទាប់ពីការចូលកាន់កាប់ទីក្រុងភ្នំពេញ សាក្សី **ខឹម ងន** ត្រូវបានបញ្ជូនទៅរាជធានីភ្នំពេញ។ បន្ទាប់ពីបញ្ចប់វគ្គអប់រំ គាត់ត្រូវបានចាត់តាំងឲ្យធ្វើការនៅក្រសួងការបរទេស ទទួលបន្ទុកអមដំណើរភ្ញៀវការបរទេសទៅតាមបណ្តាខេត្តនានា។ សាក្សីពុំត្រូវបានអនុញ្ញាតឲ្យនិយាយបញ្ហានយោបាយជាមួយភ្ញៀវការបរទេស ព្រមទាំងមិនអនុញ្ញាតឲ្យដើរហើរដោយសេរី។ នាពេលនោះ សាក្សីពុំបានស្គាល់នរណាជារដ្ឋមន្ត្រីការបរទេស ឬក៏ផ្នែកដែលខ្លួនធ្វើការឡើយ គាត់ស្គាល់តែឈ្មោះ **ហុង** ដែលជាមនុស្សណែនាំឲ្យគាត់សរសេរប្រវត្តិរូបផ្ទាល់ខ្លួន នៅពេលគាត់មកដល់ក្រសួងការបរទេស។

## III. បញ្ហាច្បាប់ និងនីតិវិធី

នាសប្តាហ៍នេះ អង្គជំនុំជម្រះបានរំឮកភាគីឲ្យសួរតែសំណួរស្ថិតក្នុងវង្វង់នៃដីកាដំណោះស្រាយ។ អង្គជំនុំជម្រះក៏បានខិតខំប្រឹងប្រែងដើម្បីធានាថា ភាគីបានគោរពទៅលើសេចក្តីសម្រេច ដែលបានសម្រេចរួចហើយពាក់ព័ន្ធនឹងការដកឯកសារចេញពីសាក្សី ប្រសិនបើសាក្សីបង្ហាញថា ខ្លួនពុំបានស្គាល់ឯកសារនោះ។ អង្គជំនុំជម្រះបានស្វះស្វែងរកនូវដំណោះស្រាយលើភាពមិនស៊ីសង្វាក់រវាងប្រតិចារិកនៃបទសម្ភាសន៍ និងខ្សែអាត់សម្លេងធ្វើនៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត។

### ក. បញ្ហាមិនស្ថិតនៅក្នុងដីកាដំណោះស្រាយ

ដីកាដំណោះស្រាយ គឺសំដៅលើ *"សេចក្តីសន្និដ្ឋានចុងក្រោយ ដែលធ្វើដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះនៅពេលបញ្ចប់ដំណើរការស៊ើបសួរ ថាតើបញ្ជូនរឿងទៅជំនុំជម្រះ ឬលើកលែងបទចោទ*

*ប្រកាន់*"[3]។ ដីកាដំណោះស្រាយ គឺមានសារៈសំខាន់ ដើម្បីធានាថា ដំណើរការសវនាការស្ថិតក្នុងដែនកំណត់ និង "សាលក្រមសម្រេចត្រឹមតែអង្គហេតុទាំងឡាយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[4]។ ពេញមួយសប្តាហ៍នេះ ការសួរដេញដោលហួសពីដែនកំណត់ ដែលមាននៅក្នុងដីកាដំណោះស្រាយ គឺជាបញ្ហាកើតឡើងម្តងហើយម្តងទៀត។ នៅថ្ងៃអង្គារ តំណាងសហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** និងសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី **អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត** បានជំទាស់នឹងសំណួររបស់មេធាវី **សុន អរុណ** នៅពេលសួរដេញដោលសាក្សី **សគឹម លុត**។ លោកស្រីមេធាវី **ស៊ីម៉ូណូហ្វត** បានថ្លែងថា មេធាវី **សុន អរុណ** បានកំពុង "ផ្តល់ទស្សនៈរបស់ខ្លួនពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ ដែលពុំមានការចងក្រងជាឯកសារ"។ មេធាវី **សុន អរុណ** បានឆ្លើយតបថា ព័ត៌មានដែលបានលើកឡើង គឺពិតជាបាន "យោងតាមឯកសារប្រវត្តិសាស្ត្រ"។ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចមិនអនុញ្ញាតឱ្យមេធាវី **សុន អរុណ** បន្តលើកបញ្ហានោះទៀតទេ ព្រោះអង្គហេតុទាំងនោះមិនស្ថិតនៅក្នុងវង្វង់នៃដីកាដំណោះស្រាយ។ (មើលចំណុចទី II.៣.ខ)

នៅថ្ងៃពុធ មេធាវីអន្តរជាតិ **ម៉ៃឃើល កាណាវ៉ាស** បានជំទាស់ទៅនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា **លីសាក់** ដែលចោទសួរសាក្សី **សៅ សារុន** អំពីមូលហេតុដែលកម្ពុជាប្រជាធិបតេយ្យបដិសេធមិនសាងសង់វត្តអារ៉ាមឡើងវិញ។ មេធាវី **កាណាវ៉ាស** បានអះអាងថាអង្គហេតុនេះមិនស្ថិតនៅក្នុងដីកាដំណោះស្រាយ។ ប្រធានអង្គជំនុំជម្រះបានច្រានចោលសំណើរបស់មេធាវី **កាណាវ៉ាស** និងអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាបន្តសំណួររបស់ខ្លួន។

នៅថ្ងៃព្រហស្បតិ៍ មេធាវី **សុន អរុណ** បានជំទាស់នឹងសំណួរពីបទពិសោធន៍របស់ភាគីទីបី ដែលតំណាងសហព្រះរាជអាជ្ញា **ច័ន្ទ តារាវស្មី** សួរទៅកាន់សាក្សី **សៅ សារុន** ។ គាត់បានបកស្រាយថា សាក្សី **សៅ សារុន** ពុំបានឃើញហេតុការណ៍នេះដោយផ្ទាល់ទេ។ ប្រធានអង្គជំនុំជម្រះបានសម្រេចតាមសំណើសុំ និងរំឭកដល់តំណាងសហព្រះរាជអាជ្ញាឱ្យកម្រិតសំណួររបស់ខ្លួន ត្រឹមតែអង្គហេតុមាននៅក្នុងដីកាដំណោះស្រាយ។

នៅក្នុងសវនាការមុនៗ អង្គជំនុំជម្រះបានយោងសំដៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២២ កញ្ញា ២០១១[5] ដើម្បីកំណត់ពីភាពទំនាក់ទំនងនៃសំណួរ និងអំណះអំណាងរបស់ភាគី ព្រមទាំង

សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ ដែលខុសពីដីកាដំណោះស្រាយ គឺសំដៅទៅលើសំណុំរឿង០០២ទាំងមូល។ ដីកាបំបែកកិច្ចដំណើរការនីតិវិធីបានកំណត់ការជំនុំជម្រះលើកទីមួយ រួមមាន (ក)រចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ (ខ)តួនាទីរបស់ជនជាប់ចោទនីមួយៗ នៅមុនពេលបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ និងរួមបញ្ចូលតួនាទីនានាដែលត្រូវបានចាត់តាំង (គ)តួនាទីរបស់ជនជាប់ក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ - ការទទួលខុសត្រូវ - ការពន្លាតនូវក្របខណ្ឌនៃសិទ្ធិអំណាច - និងខ្សែបណ្តាញទំនាក់ទំនងនៅក្នុងសម័យនោះ ដែលមានកំណត់នៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក (ឃ)គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហាទាំងឡាយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ង)អង្គហេតុចោទប្រកាន់ពាក់ព័ន្ធនឹងចលនាផ្លាស់ទីរបស់ប្រជាជន នៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ (ច) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាលការធ្វើទុក្ខបុកម្នេញ (លើកលែងដោយហេតុផលសាសនា) ការជន្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ (ដែលកន្លងមក បទល្មើសទាំងនេះជាប់ពាក់ព័ន្ធនឹងបម្លាស់ទីរបស់ប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២)។ នៅក្នុងកិច្ចដំណើរការនីតិវិធីកន្លងមក ដោយផ្អែកតាមដីកាបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះតែងតែលើកឡើងថា នៅក្នុងដំណាក់កាលនេះ គឺជាការជំនុំជម្រះលើសំណុំរឿងលេខ០០២/សវនាការទី១ ប៉ុន្តែករណីនេះពុំច្បាស់ទេថាតើការលើកឡើងរបស់អង្គ ជំនុំជម្រះនាសប្តាហ៍នេះ សំដៅទៅលើដីការដំណោះស្រាយជំនួសការលើកឡើងពីដីកាបំបែកកិច្ចដំណើរការនីតិវិធី ដែលបានបង្ហាញពីចេតនាក្នុងការពិចារណាបញ្ហាផ្សេងៗ ហួសពីដែនកំណត់នៃដីកាបំបែកកិច្ចដំណើរការនីតិវិធី ប៉ុន្តែទោះយ៉ាងណាត្រូវតែស្ថិតនៅក្នុងដែនកំណត់នៃដីកាដំណោះស្រាយ។

### ខ. ការប្រើប្រាស់ឯកសារ

នាសប្តាហ៍នេះ មេធាវីការពារក្តីអន្តរជាតិលោក **នួន ជា** បានធ្វើការជំទាស់នឹងក្រុមប្រឹក្សាជំនុំជម្រះដែលសម្រេចមិនឱ្យដាក់បង្ហាញឯកសារ ប្រសិនបើសាក្សីបានកត់សម្គាល់ថា ពួកគេមិនធ្លាប់បានឃើញឯកសារនោះពីមុនមក បើទោះបីជាឯកសារទាំងនោះមាននៅក្នុងបញ្ជីឯកសាររបស់ភាគី។ នៅថ្ងៃអង្គារ មេធាវីអន្តរជាតិ **ហ្សាស្តេ ប៉ៅ** បានលើកការជំទាស់របស់ខ្លួន នៅពេលប្រធានអង្គជំនុំជម្រះបង្គាប់ឱ្យដកឯកសារចេញ បន្ទាប់ពីសាក្សី **សគឹម ល្មុត** បានលើកថា គាត់មិនធ្លាប់បានឃើញឯកសារនោះទេ។ មេធាវី **ហ្សាស្តេ ប៉ៅ** បានអះអាងថា កាលដែលគាត់ប្រើប្រាស់ឯកសារនេះ គឺដើម្បីឱ្យសាក្សីពន្យល់ពីការនាំចេញស្រូវ។ នាពេល

នោះ។ មេធាវី **កាណាវ៉ាស** បានធ្វើការគាំទ្រលើការជំទាស់របស់មេធាវី **ហ្សាស្តើ ប៉ៅ** និងបានថ្លែងថា "គ្មានគោលការណ៍ណារារាំងដល់ភាគីមិនឲ្យសួរដេញដោលអំពីខ្លឹមសារនៃឯកសារទេ"។ ប្រធានអង្គជំនុំជម្រះបានឯកភាពទៅលើការលើកឡើងនេះ ភាគីអាចដកស្រង់នូវខ្លឹមសារនៃឯកសារទាំងនោះក្នុងការសួរដេញដោល ប៉ុន្តែមិនអនុញ្ញាតឲ្យយោង ឬដាក់បង្ហាញឯកសារនៅចំពោះសាក្សី ករណីសាក្សីពុំធ្លាប់ឃើញឯកសារនោះ។ មេធាវី **ហ្សាស្តើ ប៉ៅ** បានបញ្ចប់ការសួរដេញដោលរបស់ខ្លួន ដោយលើកឡើងថា ការដកឯកសារមិនឲ្យសួរដេញដោលសាក្សី គឺជាការដាក់កម្រិតមួយដ៏ធ្ងន់ធ្ងរចំពោះភាគី និងបន្តថា "គាត់មិនធ្លាប់បានឮពីគោលការណ៍ ហេតុអ្វីបានជាឯកសារដែលសាក្សីមិនធ្លាប់ឃើញ មិនអាចចោទសួរសាក្សីបាន"។ ប្រធានអង្គជំនុំជម្រះបានណែនាំឲ្យលោកមេធាវីពិនិត្យឡើងវិញនូវសេចក្តីសម្រេចលើកមុន និងសម្រេចបន្តកិច្ចដំណើរការជាបន្តទៀត។

ចំណោទមួយផ្សេងទៀត នៅពេលសួរដេញដោលសាក្សី **សគឹម លួត** គឺការប្រើប្រាស់ឯកសារ ដែលសាក្សីបានឃើញក្នុងពេលសម្ភាសន៍នៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត ប៉ុន្តែមិនបានឃើញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងកិច្ចដំណើរការសួរដេញដោលនេះ មានបញ្ហាធំៗបីគឺ ៖ (ក) សាក្សីមិនបានចងចាំថា គាត់បានឃើញឯកសារមួយចំនួន (ខ) ក្នុងករណីខ្លះ សាក្សីបានឃើញតែផ្នែកមួយនៃឯកសារនោះ និង (គ)ការយល់ដឹងមួយចំនួនរបស់សាក្សី គឺផ្អែកទៅលើអង្គហេតុដែលបានដាក់បង្ហាញ ពុំមែនជាការចងចាំផ្ទាល់ខ្លួន។ ចំពោះសាក្សី **សគឹម លួត** គឺចម្លើយរបស់គាត់ គឺផ្អែកតាមចំណេះដឹងផ្ទាល់ខ្លួន ដែលស្ទើរតែនាំទៅរកការសន្និដ្ឋានទាំងស្រុង ឬផ្អែកតាមឯកសារដាក់បង្ហាញនៅដំណាក់កាលចៅក្រមស៊ើបអង្កេត។

### គ. សំណើសុំខ្សែអាត់សម្លេងដើម្បីប្រៀបធៀបជាមួយការបកប្រែ

នៅពេលសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី **សៅ សារុន** ពួកគេតែងតែពឹងផ្អែកលើកំណត់ហេតុសួរចម្លើយដែលធ្វើនៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំរបស់សាក្សី។ យុត្តិសាស្ត្រនេះ គឺមានសារៈសំខាន់ណាស់ ព្រោះសាក្សីបានថ្លែងឲ្យដឹងថា ការចងចាំរបស់គាត់បានចុះខ្សោយជាលំដាប់ដោយសារជម្ងឺ។ មេធាវីអន្តរជាតិ **វែកគែន** បានធ្វើការកត់សម្គាល់ថា ក្រុមមេធាវីការពារក្តីរបស់ខ្លួនបានរកឃើញនូវភាពមិនស៊ីសង្វាក់រវាងកំណត់ហេតុនៃបទសម្ភាសន៍ និងខ្សែអាត់សម្លេង ដែលសាក្សី **សៅ សារុន** ធ្វើ

នៅដំណាក់កាលចៅក្រមស៊ើបអង្កេត។ មេធាវី **វែកគែន** បានបញ្ជាក់ថា ឈ្មោះហៅក្រៅរបស់កូនក្តីខ្លួនត្រូវបានបង្ហាញយ៉ាងជាក់ច្បាស់នៅក្នុងខ្សែអាត់សម្លេង ប៉ុន្តែមិនត្រូវបានបញ្ជាក់នៅក្នុងកំណត់ហេតុ ដែលបានអាននៅក្នុងពេលសួរដេញដោលសាក្សី **សៅ សារុន** ។ ចំណែកឯ មេធាវី **ម៉ៃខល ផេស្តមេន** ដែលជាមេធាវីការពារក្តីលោក **នួន ជា** ក៏បានដាក់សំណើសុំខ្សែអាត់សម្លេងនៃបទសម្ភាសន៍របស់សាក្សី ដែលអាចឲ្យពួកគេអាចកំណត់ពីភាពមិនស៊ីសង្វាក់នៃភស្តុតាង។ ចៅក្រម **ហ្សង់ម៉ាក់ ឡាវែន៍** បានថ្លែងថា អង្គជំនុំជម្រះមិនជំទាស់ទៅនឹងសំណើទាំងនេះទេ ប៉ុន្តែសំណើត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងកំណត់ឲ្យបានជាក់លាក់ពីផ្នែកដែលចង់បាន (ជាប្រតិចារិក ឬជាការបកប្រែ)។

## IV. ការគ្រប់គ្រងសវនាការ

ដំណើរការសវនាការនាសប្តាហ៍នេះ អង្គជំនុំជម្រះបានខិតខំប្រឹងប្រែងគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព ដើម្បីធានាពីការប្រព្រឹត្តទៅដោយឆាប់រហ័ស។ ដំណើរនិវត្តន៍ល្អប្រសើរនាពេលចុងក្រោយនេះ គឺអង្គជំនុំជម្រះបានត្រៀមសាក្សីមួយរូប (លោក **ឃឹម ងួន**) ដើម្បីបន្តផ្តល់សក្ខីកម្មនៅពេលសាក្សី **សៅ សារុន** មានបញ្ហាសុខភាព ពុំអាចបន្តសក្ខីកម្មទៀតបាន។ កំឡុងពេលដំណើរការនីតិវិធី អង្គជំនុំជម្រះបានធ្វើអន្តរាគមន៍ និងណែនាំភាគីឲ្យបញ្ចៀសសំណួរច្រំដែល និងមិនពាក់ព័ន្ធ។

### ក. ឥរិយាបថនៅក្នុងសវនាការ

បញ្ហាពាក់ព័ន្ធនឹងឥរិយាបថរបស់ភាគីបានកើតឡើងនៅក្នុងតុលាការ នៅពេលមេធាវី **វែកគែន** បានកាត់ផ្តាច់សង្វាក់នៃការសួរដេញដោលរបស់តំណាងព្រះរាជអាជ្ញា **អាប់ឌុលឡាក់** កាលពីថ្ងៃច័ន្ទ និងបានស្នើសុំថា សហព្រះរាជអាជ្ញាគួរយោងទៅលើឯកសារដែលមានព័ត៌មានច្បាស់លាស់ ពុំមែនប្រើប្រាស់ឯកសារសង្ខេបនោះទេ (កំណត់ហេតុសួរចម្លើយរបស់សាក្សី **សតឹម ល្មុត**)។ ចំណែកឯ មេធាវី **កាណាវ៉ាស** ក៏បានលើកឡើងលើចំណុចប្រហាក់ប្រហែលគ្នានេះដែរ។ ប្រធានអង្គជំនុំជម្រះបានឆ្លើយតបដោយសម្លេងខ្លាំងៗ និងចុចផ្តាច់ម៉ៃក្រូហ្វូនសម្លេងរបស់មេធាវី **វែកគែន** នៅពេលគាត់ព្យាយាមចង់បញ្ចេញមតិ។ បន្ទាប់មក ប្រធានអង្គជំនុំជម្រះបានណែនាំមេធាវី **វែកគែន** កុំឲ្យធ្វើការកាត់បង្អាក់ភាគីដទៃ ដោយបានណែនាំថា មេធាវីនឹងមាន

ឱកាសសួរដេញដោលសាក្សី។ នាពេលនោះ មេធាវី **វែកគែន** បានធ្វើការតវ៉ាដោយសម្លេងខ្លាំងៗ ទោះបីជាម៉ៃក្រូហ្វូនសម្លេងពុំដំណើរការ។

ចុងក្រោយនៃកិច្ចដំណើរការនីតិវិធីនៅថ្ងៃច័ន្ទ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានកត់សម្គាល់ នៅពេលមានការក្រោកឈររបស់មេធាវី **ហ្សាស្តេ ប៉ៅ** ដោយរំឭកថា អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យធ្វើសេចក្តីថ្លែងទេ នាពេលនេះ។ មេធាវី **ហ្សាស្តេ ប៉ៅ** បានឆ្លើយតបថា "ខ្ញុំនឹងធ្វើកំណត់សម្គាល់ខ្លីបំផុត" និងសុំឱ្យអង្គជំនុំជម្រះកុំ "ចុចផ្តាច់ម៉ៃក្រូហ្វូនសម្លង"។ លោកមេធាវីបានជម្រាបដល់អង្គជំនុំជម្រះថា ក្រុមមេធាវីការពារក្តីបានឯកភាពគ្នាក្នុងការផ្លាស់ប្តូរ លំដាប់នៃការសួរដេញដោលសាក្សី **សគីម ល្មុត**។

**ខ. វត្តមាន**

នាសប្តាហ៍នេះ លើកលែងតែលោក **អៀង សារី** ដែលពុំមានវត្តមាននៅក្នុងបន្ទប់សវនាការ ក្រៅពីនេះជនជាប់ចោទ **នួន ជា** និង **ខៀវ សំផន** មានវត្តមាននៅពេលសវនាការ។កាលពីសប្តាហ៍មុន ជនជាប់ចោទ **អៀង សារី** បានជូនដំណឹងដល់មេធាវីរបស់ខ្លួនថា គាត់នៅតែមានសភាពវិលមុខនៅពេលអង្គុយ ក្នុងរយៈពេលមួយ[6]។ ដូច្នេះ ប្រធានអង្គជំនុំជម្រះបានបង្គាប់ឱ្យក្រុមមេធាវីការពារក្តីលោក **អៀង សារី** ដាក់នូវលិខិតជាផ្លូវការណ៍ អំពីការលះបង់សិទ្ធិមិនចូលរួមតាមដានសវនាការដោយផ្ទាល់។ តាមទម្លាប់ នៅពេលបញ្ចប់វគ្គសវនាការពេលព្រឹក ជនជាប់ចោទ **នួន ជា** បានស្នើសុំចាកចេញទៅចូលរួមតាមដានពីចម្ងាយពីបន្ទប់រងចាំ ហើយមានតែជនជាប់ចោទ **ខៀវ សំផន** ម្នាក់ប៉ុណ្ណោះ ដែលមានវត្តមាននៅក្នុងសវនាការ។

**វត្តមានរបស់សាធារណៈជន** ៖ ទោះបីជាមានភ្លៀងធ្លាក់ពេញមួយសប្តាហ៍នេះ ក៏ចំនួនអ្នកចូលរួមតាមដានសវនាការនៅមានកម្រិតខ្ពស់ ដែលមានប្រមាណជា ១,៦៩៤នាក់ ក្នុងរយៈពេលបួនថ្ងៃនេះ រួមមាន សិស្សនិស្សិត និងអ្នកភូមិ មកពីខេត្តស្វាយរៀង ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពតវិទ្យាល័យពងទឹក និងមហាវិទ្យាល័យអាស៊ីអឺរ៉ុប។

## ក. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្ដើម | ការសម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | ការសម្រាកពេលរសៀល | បិទសវនាការ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ០៤/០៦/១២ | ៩:០០ | ១០:៣០-១០:៥០ | ១១:៥៤-១៣:៣០ | ១៤:៤២-១៥:០០ | ១៥:៤៣ | ៤ម៉ោងនិង៣០នាទី |
| ថ្ងៃអង្គារ ០៥/០៦/១២ | ៩:០០ | ១០:៣២-១០:៥១ | ១២:១១-១៣:៣២ | ១៤:៤២-១៥:០១ | ១៦:០២ | ៥ ម៉ោង |
| ថ្ងៃពុធ ០៦/០៦/១២ | ៩:០០ | ១០:៣០-១០:៥០ | ១២:០២-១៣:២៩ | ១៤:៣១-១៥:០១ | ១៦:០៣ | ៤ម៉ោងនិង ៤៦ នាទី |
| ថ្ងៃព្រហស្បតិ៍ ០៧/០៦/១២ | ៩:០០ | ១០:៣២-១១:០០ | ១២:០៥-១៣:៣២ | ១៤:៤៤-១៥:០០ | ១៦:០០ | ៤ ម៉ោងនិង ៤៩ នាទី |

| | |
|---|---|
| ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយវគ្គ ៖ | **៤ម៉ោង៤៦នាទី** |
| ចំនួយម៉ោងសរុបក្នុងសប្ដាហ៍នេះ ៖ | **១៩ម៉ោង៤នាទី** |
| ចំនួនសរុបនៃម៉ោងថ្ងៃនិងសប្ដាហ៍ ៖ | **២៩៩ម៉ោង៥៣នាទី** |

**៧០ថ្ងៃ និង២១សប្ដាហ៍**

EAST-WEST CENTER

AIJI TRIAL MONITORING

WCSC
WAR CRIMES STUDIES CENTER
UNIVERSITY OF CALIFORNIA, BERKELEY

[*] AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Mary Kristerie A. Baleva, Faith Suzzette Delos Reyes, Adair Fincher, Kounila Keo, Vidjia Phun, Juan Pablo Stein, Alvin Yap, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] Kaing Guek Eav, alias "Duch", during his testimony before the TC, had confirmed that Seua Vasi alias "Comrade Doeun" was the "Chairman of Political Office 870, later transferred to the Ministry of Commerce". See CASE 002 KRT TRIAL MONITOR Issue No. 16, Week 11 of Evidentiary Hearings (26-29 March 2012). 3.

[2] The Closing Order describes Borei Keila as a meeting place, also referred to as K-6. At Borei Keila, Nuon Chea was said to have conducted several mass political trainings where he taught the policies of the CPK to Party cadres and workers in Phnom Penh. OCIJ. "Closing Order" (15 September 2010). D427**.** Paragraphs 59 and 886.

[3] The Internal Rules defines the Closing Order as the "final order made by the Co-Investigating Judges or the Pre-Trial Chamber at the end of the judicial investigation, whether Indictment or Dismissal Order." Extraordinary Chambers in the Courts of Cambodia Internal Rules (Rev. 8), as revised on 3 August 2011. "Glossary". 80.

[4] Clarens, Margarita. *Analysis of the ECCC Closing Order Indicting Kaing Guek Eav (Duch)*. Available at <http://www.d.dccam.org>.

[5] Trial Chamber. "Severance Order" (22 Septmeber 2011). E124. Para. 1; 5. 1; 3.

[6] See CASE 002 KRT TRIAL MONITOR Issue No. 23, Week 18 of Evidentiary Hearings (21,23 May 2012). 2.